# អន្តរាគមន៍ ឯកឧត្តម គៀត សុគន្ធ
# ក្នុងឱកាសសន្និសីទស្តីពី កម្មវិធីស្រាវជ្រាវលើការចូលរួមរបស់កម្ពុជា
# ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ភ្នំពេញ

**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីភ្ញៀវជាតិ អន្តរជាតិ ជាទីគោរព!**

**សូមគោរពលោក សុខ ហាច នាយកវិទ្យាស្ថាន សេដ្ឋកិច្ចកម្ពុជា ជាទីរាប់អានដ៏ខ្ពង់ខ្ពស់ ។**

ក្នុងនាមឯកឧត្តម **កឹម សុខា** នាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនដល់នាយក នឹងសហការី នៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ដែលបានផ្តល់កិត្តិយសដល់យើងខ្ញុំចូលរួមសម្តែងការរីករាយ អបអរសាទរក្នុងពិធីបើកសម្ពោធជាផ្លូវការនូវវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា កាលពីពេលព្រឹកមិញនេះ និងបានចូលរួមមតិក្នុងពេលនេះលើប្រធានបទមួយយ៉ាងសំខាន់ស្តីពី ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក W T O របស់ព្រះរាជាណាចក្រកម្ពុជាយើង ។

ដូច្នេះ ខ្ញុំសូមថ្លែងនូវការកោតសសើរ ចំពោះការកើតឡើង នៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ដែលជាតម្រូវការចាំបាច់សំរាប់សង្គមខ្មែរយើងនៅក្នុងកាលទេសៈសព្វថ្ងៃ និងសូមប្រសិទ្ធិពរ សូមឱ្យវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជានៅក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ប្រកបដោយសមត្ថភាពនៃលោកនាយក សុខ ហាច នឹងសហការី បានប្រកបដោយជោគជ័យដូចក្តីបំណង ដើម្បីជាឧត្តមប្រយោជន៏នៃប្រទេសជាតិ ប្រជាពលរដ្ឋខ្មែរកុំបីខានឡើយ ។

ទាក់ទិនទៅលើរឿងចូលជាសមាជិកនៃអង្គការ ពាណិជ្ជកម្មពិភពលោក W T O របស់ប្រទេសកម្ពុជាជាពិសេសការសំរេចបាននៃសមធម៌ និងយុត្តិធម៌សង្គម Achieving equity and Social justice ; the ethical implications on work and business ឬ ផលប៉ះពាល់លើការងារ និងធុរៈកិច្ច ខ្ញុំសូមចូលរួមមតិខ្លះលើចំណុចដូចតទៅ :

**១- កង្វះនៃការផ្សព្វផ្សាយពត៌មាន តម្លាភាព ឬការចូលរួមពីប្រជាពលរដ្ឋក្នុងការសំរេច :**

lack of information, transparency or participation in decision making from the people

យើងទាំងអស់គ្នាបានដឹងរួចហើយថា ថ្វីត្បិតតែរដ្ឋាភិបាលកម្ពុជា បានចំណាយពេលយ៉ាងយូរ មុនពេលបានចូលជាសមាជិកទី១៤៧នៃអង្គការពាណិជ្ជកម្មពិភពលោកក៏ដោយ ក៏ផលប៉ះពាល់នៃការចូលនេះមិនត្រូវបានរាជរដ្ឋាភិបាលយកមកធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីជាមូលដ្ឋាន នៃការពិចារណារបស់ប្រជាពលរដ្ឋ ពាណិជ្ជករ កសិករ កម្មករ ដែលជាដៃគូយ៉ាងសំខាន់ក្នុងការអនុវត្តន៍ នូវគោលនយោបាយ និងជាអ្នកទទួលនូវផលប៉ះពាល់ដោយផ្ទាល់ពីការសំរេចចូលអង្គការពាណិជ្ជកម្មពិភពលោកនោះទេ ។ ប្រការនេះ គឺជាកង្វះខាតមួយធំណាស់របស់រាជរដ្ឋាភិបាលមួយដែលជារាជរដ្ឋាភិបាល នៅក្នុងរបបប្រជាធិបតេយ្យ ហើយដាក់វាសនាវិនិយោគិនខ្មែរ ពាណិជ្ជករខ្មែរ កម្មករខ្មែរ កសិករខ្មែរ ទីបំផុតប្រជាពលរដ្ឋខ្មែរឱ្យស្ថិតនៅ ក្រោមសេចក្តីសំរេចសឹងតែអត្តនោមត្ត នៃអ្នកកាន់អំណាច ។

## ២-<u>អយុត្តិធម៌ចំពោះកសិករខ្មែរ</u> Unfair to the Khmer Farmers

អ្វីដែលយើងទាំងគ្នាបានមើលឃើញជាចម្បងនោះគឺប្រទេសកម្ពុជាបានសុខចិត្តចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ថ្វីត្បិតតែសម្បទាន និងការប្តេជ្ញាចិត្តរបស់ខ្លួនមានទំហំហួសមាឌក៏ដោយ ។ សម្បទាន ដ៏ធំធេងហួសមាឌរបស់ប្រទេសកម្ពុជានេះ គឺការបិទផ្សារកសិផលខ្មែរនៅបរទេស ហើយបើកចំហរទីផ្សារកសិផលបរទេសនៅក្នុងប្រទេសខ្មែរ ។

ការបើកចំហរទីផ្សារកសិផលបរទេស នៅក្នុងប្រទេសខ្មែរ និងការបិទផ្សារកសិផលខ្មែរនៅបរទេស គឺតាមរយៈការយកពន្ធនាំចូលកសិផលបរទេសយ៉ាងទាប និងការសន្យាមិនផ្តល់ប្រាក់ជំនួយកសិផលខ្មែរឱ្យមានលទ្ធភាពអាចប្រកួតប្រជែងបាន។ បើយើងពិនិត្យការសន្យារបស់ខ្មែរលើបញ្ហាកសិផលទៅនិង ទង្វើរបស់សមាជិកឯទៀត១ នៃអង្គការពាណិជ្ជកម្មពិភពលោក ដែលជាប្រទេសសមាជិក ជាអ្នកមាននោះ យើងឃើញថា ខ្មែរយើងសន្យាធ្វើសម្បទានច្រើនជាងប្រទេសអ្នកមានទាំងនោះដល់ទៅពីរដង ឬ៣ដង ដែលជាការពន្លិចកសិករខ្មែរ យើងឱ្យស្ថិតនៅក្នុងស្ថានភាពចាញ់ប្រៀប ឬ បាត់បង់សមត្ថភាពប្រកួតប្រជែង ហើយទីបំផុត គឺត្រូវបាត់បង់ការងារ បាត់បង់អាជីព របស់ខ្លួនជាប្រពៃណី មកហើយនោះ ។ បើយើងពិនិត្យរឿងសម្បទានខាងលើ ទៅលើបរិបទនៃសង្គមខ្មែរនោះយើង និងឃើញថារដ្ឋាភិបាលខ្មែរ បានធ្វើសម្បទានដោយជាន់ឈ្លីចោលនូវស្រទាប់ដ៏ធំនៃសង្គម និងមូលដ្ឋាននៃសេដ្ឋកិច្ចខ្មែរគឺ កសិករ-កសិកម្ម ។ សង្គមខ្មែរមានកសិករ៨៥%ពោលគឺប្រហែល១០,២០០,០០០នាក់ ដែលរស់នៅដោយសារកសិកម្មកសាងសេដ្ឋកិច្ចក្នុងវិស័យកសិកម្ម ។

ឥឡូវនេះ កម្ពុជាក្លាយជាសមាជិក W T O វាសនាកសិករទាំងនោះ ត្រូវតែញែកឱ្យចូលក្នុងសភាពបាត់បង់សុពលភាពប្រកួតប្រជែង ។ រឿងនេះអយុត្តិធម៌ចំពោះកសិករខ្មែរ ក៏វាជារឿងបំបាត់ចោលនូវវិស័យសេដ្ឋកិច្ចមួយដ៏ធំរបស់ខ្មែរដែ ។

បើយើងពិនិត្យមើលលើការស្រាវជ្រាវរបស់លោក គឹម ផល្លា និងអ្នកស្រី ទុយ ចរិយា នៃវិទ្យា ស្ថានសេដ្ឋកិច្ចកម្ពុជាបានឱ្យដឹងថា ក្នុងចំណោមកម្មករដែលមានភាពងាយរងគ្រោះហើយមកធ្វើការនៅភ្នំពេញ គឺមាន២៥ %

ចេញមកពីខេត្តព្រៃវែង ។ ហើយបើតាមការសង្កេតផ្ទាល់របស់ខ្ញុំទៀត ខ្ញុំឃើញប្រជាពលរដ្ឋទាំងនោះចូលមកភ្នំពេញគឺបណ្តាលមកពីខ្លួនគ្មានទឹកធ្វើស្រែ ឬទឹកលិចស្រែរបស់ខ្លួន ពោល គឺបាត់បង់លទ្ធភាពក្នុងការប្រកបកសិកម្ម ។

ឥឡូវនេះ ប្រទេសកម្ពុជាយើងចូលជាសមាជិក W T O ដោយផាត់ចោលនូវសមត្ថភាពប្រកួតប្រជែងរបស់កសិករខ្មែរ ទីបំផុតកសិករទាំងនោះ ដែលមកពីស្រុក ខេត្ត ឯទៀតៗ នឹងបោះបង់ការងាររបស់ខ្លួនចោល ហើយរត់ចូលមករកការងារនៅភ្នំពេញ ដែលជាកត្តាបង្ក នូវភាពច្របូកច្របល់សង្គមយ៉ាងខ្លាំង នៅក្នុងក្រុង ។

ជាការពិតណាស់ តាមរយៈការចូលសមាជិក W T O នេះ គឺជាការជួយដល់កម្មករកាត់ដេរ ដែលសព្វថ្ងៃមាន ចំនួនប្រហែល ២០០,០០០ នាក់ ហើយដែលអាចជួយចិញ្ចឹមដល់ឪពុក ម្តាយ ឬ ញាតិមិត្តចំនួនប្រហែល ១,០០០,០០០នាក់ ទៀត ។ តែការនេះ ដូចជាមិនទាន់ច្បាស់ថា បន្ទាប់ពីប្រទេសខ្មែរអស់កូកាក្នុងឆ្នាំ២០០៤ទៅ ឧស្សាហកម្មផ្នែកកាត់ដេរខ្មែរ អាចរីកចំរើនណាស់ ព្រោះការពង្រីកនេះវាទាក់ទិនទៅ និងវិនិយោគជាពិសេស វិនិយោគបរទេសនេះ បើមិនទាន់គិតដល់ការប្រកួតប្រជែងយកទីផ្សារពីប្រទេសឯទៀតៗ ដូចជាប្រទេសចិន ឬឥណ្ឌា ជាដើម ។ ចំណុចត្រង់នេះ យើងលើកយកវិនិយោគបរទេសមកនិយាយ ព្រោះវិនិយោគបរទេសនេះ អាចរីកចំរើនបានគឺ អាស្រ័យលើច្បាប់ សន្តិសុខ ភាពស្អាតស្អំ ។ ល ។ តើប្រទេសខ្មែរយើងដោះស្រាយបញ្ហាទាំងអស់នេះបានឬទៅ?

សរុបសេចក្តីមក រាជរដ្ឋាភិបាលខ្មែរ សំរេចចូលនេះ គឺហាក់ដូចជា ដាក់វាសនា នៃកម្មករកាត់ដេរខ្មែរ ក្នុងភាពប្រថុយប្រថានណាស់ ។

**៣-<u>វប្បធម៌ជូនតាមសំណើរ</u>** Culture of generosity

យើងទាំងអស់គ្នាដឹងហើយថា ប្រទេសកម្ពុជាយើង គឺជាប្រទេសដែលមានការអភិវឌ្ឍន៍ទន់ខ្សោយទី១ដែលបានចូលជាសមាជិក W T O ហើយដែលជាសមាជិកទី១៤៧ នៃអង្គការនេះ ។ បើនិយាយឱ្យខ្លី គឺជាការសាកល្បងនៃអង្គការ ហើយបើនិយាយពីការសាកល្បង គឺគេមិនតឹងតែង ឬគាបខ្លាំងពេកទេ ព្រោះគេដឹងថា ប្រទេសខ្មែរជាប្រទេសក្រីក្រ ។ ដូច្នេះការសូមទាមទារផ្សេងៗ ពីសមាជិកឯទៀតៗ គឺគ្រាន់តែធ្វើលើការចាំបាច់ប៉ុណ្ណោះ ។ ចំណែកប្រទេសកម្ពុជា គឺបានធ្វើសម្បទានដល់គេទាំងអស់ ។ រហូតដល់ផ្នែកខ្លះដូចជា ផ្នែកកម្មសិទ្ធបញ្ញា ជាដើមដែលធម្មតាគេអនុញ្ញាតពេលឱ្យយើងរហូតឆ្នាំ២០១៦ យើងបែរជាសុខចិត្តសន្យាត្រឹមឆ្នាំ២០០៧ ពោលគឺ១០ឆ្នាំមុនពេលកំណត់ ។ ការសន្យាអនុវត្តឱ្យបានពេញលេញ នូវច្បាប់កម្មសិទ្ធិបញ្ញា បន្ទាប់ពីឆ្នាំ២០០៧ទៅ គឺជំរុញឱ្យថ្នាំពេទ្យ សៀវភៅ ឬអ្វីៗផ្សេងៗទៀត ដែលយើងធ្លាប់ផលិតតាមការអនុញ្ញាតពីម្ចាស់ដើមនោះមានតម្លៃខ្ពស់ ។ ការឡើងតំលៃខ្ពស់នេះ គឺអ្នកជំងឺ ឬនិស្សិត ឬអ្នកប្រើប្រាស់ ដែលជាប្រជាពលរដ្ឋខ្មែរនេះ ជាអ្នកចេញ ។ នេះគឺវប្បធម៌មួយដែលគួរឱ្យបោះបង់ព្រោះវាបណ្តាលឱ្យ ប្រជាពលខ្មែរចំណាយអស់យ៉ាងច្រើនដែលជាការមិនចាំបាច់ ។

**៤-<u>កិច្ចសន្យាខ្យល់</u>** White elephant promises

ទន្ទឹមនិងសម្បទានផ្សេងៗ ដូចបានរៀបរាប់ខាងលើប្រទេសកម្ពុជាយើងបានសន្យាធ្វើការកែប្រែនូវច្បាប់ទន្លាប់ បទបញ្ជានិងការគ្រប់គ្រងមួយចំនួនធំ ។ ហើយបើតាមការគន់គូររបស់អ្នកបច្ចេកទេសខ្លះ បានឱ្យដឹងថា ដើម្បីសំរេចនូវការសន្យាទាំងនេះប្រទេសកម្ពុជាត្រូវតាក់តែងច្បាប់  និងបទបញ្ជាសំខាន់ៗ  ឱ្យបាន២ក្នុងមួយខែ ដែលជាតួលេខមួយខ្ពស់ហួសពីភាពជាក់ស្តែងកន្លងមក  ។ បើតាមការពិសោធន៏កន្លងមក  គ្រាន់តែច្បាប់ប្រឆាំងអំពើពុករលួយ  និងច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ  គឺយើងបានចំណាយពេលជាង១០ឆ្នាំហើយ  នៅតែច្បាប់នោះមិនទាន់បានចេញ  ឬដាក់ឱ្យអនុវត្តន៏ផង ។ ដូច្នេះការសន្យារបស់រាជរដ្ឋាភិបាលក្នុងការកែប្រែច្បាប់ ទន្លាប់  បទបញ្ជា នេះគឺដូចជាធំធេងណាស់ ។

ហើយបើយើងពិនិត្យទៅក្រុមអ្នកដឹកនាំ  ដែលទើបជាប់ឆ្នោតថ្មី  ស្ថានការសព្វថ្ងៃក្តីសង្ឃឹមថា  អាចអនុវត្តន៏កិច្ចសន្យាទាំងនោះបាន គឺមានតិចតួចបំផុត ។

សំនួរសួរថា  ហេតុដូចម្តេចបានជារដ្ឋាភិបាលត្រូវតែធ្វើកិច្ចសន្យាធំធេងយ៉ាងដូច្នេះ  ?  ចម្លើយគឺថាយើងត្រូវរៀបចំប្រទេសយើង  ឱ្យក្លាយទៅជានីតិរដ្ឋ  មានច្បាប់គ្រប់គ្រង  មានការគោរពច្បាប់  គោរពសិទ្ធិសេរីភាព  និងប្រជាធិបតេយ្យដើម្បីផ្តល់នូវសន្តិសុខ  កិច្ចធានាដល់វិនិយោគទុន  ជាពិសេសទុនបរទេស  ដើម្បីទាក់ទាញទុនបរទេសឱ្យយកមកវិនិយោគនៅក្នុងស្រុកខ្មែរ ។ បើគ្មានវិនិយោគទុនបរទេសទេ   ការអភិវឌ្ឍន៏សេដ្ឋកិច្ចទូរទៅនៅក្នុងប្រទេសខ្មែរ គឺមិនអាចទៅរួចឡើយ លើកលែងតែទុនក្នុងស្រុកដ៏តិចតួច ដែលវិនិយោគិនជាអ្នកដែលមានខ្នងបង្អែកតែប៉ុណ្ណោះ ។

នៅពេលគ្មានការកែប្រែដូចពាក្យសន្យា  ឬមានការកែប្រែយឺតយ៉ាវនោះ  ទុនបរទេសដែលយកមកវិនិយោគនៅក្នុងស្រុកខ្មែរក៏គ្មាន  ឬក៏យឺតយ៉ាវដែរ   ។  ហើយបើគ្មានវិនិយោគបរទស   ក៏គ្មានការងារគ្រប់គ្រាន់ជូនដល់កម្លាំងពលកម្មរបស់ខ្មែរដែរ  ។ហើយបើវិនិយោគបរទេសមានការយឺតយ៉ាវក៏ទីផ្សារការងាររបស់ពលករខ្មែរមានការយឺតយ៉ាវ

ដែរ  ។  ហើយបើតាមស្ថិតិខ្លះ  បានឱ្យដឹងថាកម្លាំងពលករខ្មែរ  ក្នុងមួយឆ្នាំៗមានកើនចំនួន២០០,០០០នាក់យ៉ាងតិច ។ បើគ្មានការកែប្រែដូចពាក្យសន្យាតើផ្សារការងារអាចស្រូបយកកម្លាំងពលករបានប៉ុន្មាននាក់?  ហើយកម្លាំងពលករដែលសល់ក្នុងមួយឆ្នាំៗរាប់សែននាក់នោះនិងក្លាយទៅជាអ្វី? រស់នៅយ៉ាងដូចម្តេច? សង្គមនោះនិងក្លាយទៅជាយ៉ាងណា? ដូច្នេះមានតែក្តីសង្ឃឹមទៅលើអច្ឆរិយនៃអនាគតរដ្ឋសភា  រាជរដ្ឋាភិបាល  ដែលត្រូវកើតនៅក្នុងអនាគតដ៏ខ្លីខាងមុខនេះតែប៉ុណ្ណោះ ។ ជាពិសេសទៅទៀតខ្ញុំសង្ឃឹមថា ថ្ងៃទី៥ ខែវិច្ឆិកា ខាងមុខនេះ និងនាំមកនូវការចាប់ផ្តើមនៃភាពអច្ឆរិយមិនខាន ។

នៅត្រង់ចំណុចនេះ យើងគួរពិនិត្យលើលទ្ធផលនៃការស្រាវជ្រាវរបស់  លោក សុខ ហាច  ដែលបានរកឃើញ

ថាកត្តាដែលនាំឱ្យបរិដ្ឋាន ធុរៈកិច្ចមានភាពអន់ គឺទី១ អស្ថិរភាពនយោបាយ ហើយទី២គឺអំពើពុករលួយ ។ ដូច្នេះការបំបាត់អស្ថិរភាពនយោបាយ  និងអំពើពុករលួយ  គឺជាការចាំបាច់  ហើយចម្បងបំផុត  ដើម្បីជំរុញឱ្យមានវិនិយោគបរទេសចូលមកស្រុកខ្មែរ  ។ នៅក្នុងបរិបទនយោបាយស្រុកខ្មែរដែលដឹកនាំដោយក្រុមអេលីត  មួយក្រុមហើយដែលមានមុខដដែលៗ  ការបំបាត់នូវអស្ថិរភាពនយោបាយមានការងាយបំផុត  ។ ព្រោះការបំបាត់អស្ថិរភាពនយោបាយ  គឺមិនមែន  នៅលើការកសាងគ្រឹះ  បណ្តុះវប្បធម៌  ដើម្បីស្ថិរភាពជានិរន្ត  នៃនយោបាយខ្មែរទេ  ។  ផ្ទុយទៅវិញ  ការបំបាត់អស្ថិរភាព  នយោបាយ  ឬបង្កស្ថិរភាពនយោបាយ  គឺស្ថិតនៅលើបបូរមាត់  ឬចិត្តផ្ទាល់របស់ក្រុមអេលីត  ៣ឬ៤នាក់  នោះតែប៉ុណ្ណោះ ដែលមិនមែនជាការធានានូវសុវត្ថិភាព ដល់វិនិយោគទុនបរទេសឡើយ  ។ ជាពិសេសទៅទៀត

តាមបទពិសោធន៏កន្លងមក ការបំបាត់អស្ថិរភាពនយោបាយ ដោយកំណត់ត្រឹម តែការត្រូវរ៉ូវគ្នាដោយមាត់ទទេ រវាងក្រុមអេលីត គឺច្រើនតែមាន និន្នាការនាំទៅរកអំពើផ្ដាច់ការ ប្រឆាំងលទ្ធិប្រជាធិបតេយ្យ បង្កើនអំពើពុករលួយ ដែលជាកត្តាអវិជ្ជមានធំទី២ នៃវិនិយោគបរទេស។ ដូច្នេះស្ថិតនៅក្នុងសភាពយឺតយ៉ាវ និងមិនពិតប្រាកដនេះ គឺបាន រុញច្រានពាណិជ្ជករខ្មែរ កសិករខ្មែរ ពលករខ្មែរ ឱ្យធ្លាក់ទៅក្នុងសភាពមួយដែល **ស្លាប់មុនពេលរស់** ។

## <u>ដំណោះស្រាយ</u>

### ៥-<u>សំណាញ់សុវត្ថិភាព</u> <u>ការប្រកួតប្រជែង</u> <u>ដើមទុន</u> <u>ចំណេះដឹង</u>

Safety net ,competition ,capital and knowledge

ទោះជាយ៉ាងណាក៏ដោយ យើងមិនអាចងាកថយក្រោយបានទេ ចំពោះការចូលជាសមាជិកភាពនៃ WTO នេះ ហើយក៏យើងមិនត្រូវងុបងុលក្នុងទុទិដ្ឋិនិយមដែរ ព្រោះយើងមិនអាចរស់ក្នុងភាពឯកោក្នុងសម័យសកលភាវូបនីយកម្មនេះបានឡើយ ។ បើនិយាយតាមគោលការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺយើងត្រូវតែប្រថុយ បើមិនប្រថុយ ក៏មិនមានការកែប្រែដែរ ។ ប៉ុន្តែការប្រថុយរបស់យើង ត្រូវមានសំណាញ់សុវត្ថិភាពចាំត្រងកសិករ កម្មករ ពាណិជ្ជករ សហគ្រិនជាតិ ក៏ដូចជាប្រជាពលរដ្ឋឯទៀត១ ដែលគ្មានលទ្ធភាព ឬសមត្ថភាពគ្រប់គ្រាន់ ទាំងផ្នែកដើមទុន ចំណេះដឹង ក្នុងការចូលប្រកួតប្រជែងមួយ ក្នុងកាលទេសៈអន្តរកាលដែលប្រៀបបានយកកូនក្មេងទៅរត់ប្រណាំងជាមួយមនុស្សពេញវ័យនោះ ឱ្យមានលទ្ធភាពអាចទប់ទល់ខ្លួន រហូតដល់រាជរដ្ឋាភិបាលអាចធ្វើការកែប្រែដូចកិច្ចសន្យារបស់ខ្លួនបានជាមុន ។

សរុបសេចក្ដីមក ទោះបីការចូលជាសមាជិក WTO របស់កម្ពុជាហាក់ដូចជាមានភាពទុំមុនស្រគាល ធ្វើឱ្យបាត់បង់ នូវរសជាតិខ្លះក៏ដោយ ក៏ជាការតម្រូវមួយគឺរិតខ្ពស់ដល់រដ្ឋសភាខ្មែរ រាជរដ្ឋាភិបាលខ្មែរឱ្យយល់ថាការ **ស្លាប់មុនរស់** របស់ពាណិជ្ជករខ្មែរ កសិករខ្មែ កម្មករខ្មែរ គឺជាបញ្ហាមួយដ៏ធំដែលគេត្រូវដោះស្រាយមុនអ្វី១ ទាំងអស់ ហើយ ឱ្យផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស នូវចក្ខុវិស័យ ការគ្រប់គ្រង និងរាល់ទង្វើរបស់ខ្លួន ដើម្បីឈោងចាប់យក នូវឧត្តមប្រយោជន៏ របស់ប្រជាពលរដ្ឋ និងប្រទេសជាតិខ្មែរយើង ។

សូមអរព្រះគុណ!
សូមអរគុណ !

ភ្នំពេញ.ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣

**គៀត សុគន្ធ**